**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិ**
**គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា សូមជម្រាបជូនសាធារណជនជ្រាបថា ផ្អែកតាមសំណើរបស់ប្រជាពលរដ្ឋចំនួន ១០៣ គ្រួសារដែលបានរស់នៅ និងកាន់កាប់ដីជាក់ស្តែងតាំងពីឆ្នាំ ១៩៨៦ មក នៅពាយកំពេញ ស្ថិតនៅភូមិ ១ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅខែសីហា ឆ្នាំ ២០១៦ រាជរដ្ឋាភិបាលបានសម្រេចធ្វើប្រទានកម្មដីនៅពាយកំពេញនេះជូនប្រជាពលរដ្ឋទាំង ១០៣ គ្រួសារជាកម្មសិទ្ធិ។

ក្រុមការងាររៀបចំផែនការប្រើប្រាស់ដីតំបន់ពាយកំពេញ ត្រូវបានបង្កើតឡើង តាមរយៈសេចក្តីសម្រេចលេខ ០៦៥ ជនស.សសរ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ និងបានធ្វើការសិក្សារៀបចំផែនការប្រើប្រាស់ដី រួមទាំងប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាមូលដ្ឋានបម្រើដល់ការអភិវឌ្ឍតំបន់និងការកែលម្អឆ្នេរសមុទ្រប្រកបដោយសោភ័ណភាព រក្សាបាននិរភាពបរិស្ថាន និងធនធានធម្មជាតិ។

ចាប់ពីពេលនោះមក ការកសាងបណ្តាញផ្លូវបេតុង ប្រព័ន្ធលូ គម្រោងអភិវឌ្ឍនានា និងការកែលម្អឆ្នេរថ្មីឱ្យទៅជាឆ្នេរខ្សាច់ដែលអាចឱ្យសាធារណជននិងភ្ញៀវទេសចរចេញចូលកំសាន្តបាន ត្រូវបាននិងកំពុងដំណើរការរៀបចំ ដើម្បីបម្រើប្រយោជន៍សាធារណៈនិងរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍ ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល ផ្ទុយពីព័ត៌មានអវិជ្ជមាននាពេលថ្មីៗនេះ ដែលផ្សព្វផ្សាយថា មានការចាក់ដីចូលឆ្នេរសមុទ្រនៅពាយកំពេញ។

លើសពីនេះ កាលពីថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ ២០៣០ សំដៅធានាការអភិវឌ្ឍខេត្តព្រះសីហនុប្រកបដោយចីរភាព។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃអាទិត្យ ១៤ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៨

អាសយដ្ឋាន : ផ្លូវលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com